ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy

លេខ ...............

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

រាជធានីភ្នំពេញ, ថ្ងៃទី ...... ខែ ...... ឆ្នាំ ២០......

# រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

## ជំរាបជូន

**ក្រុមហ៊ុន** CAMBODIA INTERNATIONAL INVESTMENT DEVELOPMENT GROUP Co., Ltd.

**ក្រុមហ៊ុន** INNER-MONGOLIA ERDOS HONGJUN INVESTMENT Co., Ltd.

**កម្មវត្ថុ:** ករណីសំណើសុំទទួលស្គាល់ការចាប់ដៃគូសហការរវាង ក្រុមហ៊ុន CAMBODIA INTERNATIONAL INVESTMENT DEVELOPMENT GROUP Co., Ltd និងក្រុមហ៊ុន INNER-MONGOLIA ERDOS HONGJUN INVESTMENT Co., Ltd ដើម្បីធ្វើការសិក្សាស្រាវជ្រាវរ៉ែបុកស៊ីតនៅតំបន់ភ្នំទូគួរ ស្រុកអូររាំង និងស្រុកសែនមនោរម្យ ខេត្តមណ្ឌលគីរី ។

**យោង:** - កិច្ចព្រមព្រៀងស្តីពីការសិក្សាស្រាវជ្រាវរ៉ែបុកស៊ីតនៅតំបន់ភ្នំទូគួរ ស្រុកអូររាំង និងស្រុកសែនមនោរម្យ ខេត្ត-មណ្ឌលគីរី រវាងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ជាមួយក្រុមហ៊ុន CAMBODIA INTERNATIONAL INVESTMENT DEVELOPMENT GROUP Co., Ltd ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១០។

- លិខិតស្នើសុំចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១១ របស់ក្រុមហ៊ុន CAMBODIA INTERNATIONAL INVESTMENT DEVELOPMENT GROUP Co., Ltd ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជំរាបជូនក្រុមហ៊ុនទាំងពីរជ្រាបថា ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល សូមគាំទ្រ និងទទួលស្គាល់ចំពោះការចាប់ដៃគូសហការរវាង ក្រុមហ៊ុន CAMBODIA INTERNATIONAL INVESTMENT DEVELOPMENT GROUP Co., Ltd និងក្រុមហ៊ុន INNER-MONGOLIA ERDOS HONGJUN INVESTMENT Co., Ltd ដើម្បីធ្វើការសិក្សាស្រាវជ្រាវរ៉ែបុកស៊ីត នៅតំបន់ភ្នំទូគួរ ស្រុកអូររាំង និងស្រុកសែនមនោរម្យ ខេត្តមណ្ឌលគីរី តាមសំណើ។

ចំពោះការរៀបចំបង្កើតក្រុមហ៊ុនចម្រុះទុនថ្មីឈ្មោះ C.I.I.D.G ERDOS HONGJUN ALUMINUM INDUSTRY Co., Ltd សូមក្រុមហ៊ុនទាំងពីរអនុវត្តតាមនីតិវិធីច្បាប់របស់ព្រះរាជាណាចក្រកម្ពុជាជាធរមាន។

អាស្រ័យហេតុនេះ សូមក្រុមហ៊ុនទាំងពីរជ្រាប និងសហការអនុវត្តប្រតិបត្តិការរ៉ែ ដោយអនុលោមទៅតាមប្រការទាំងឡាយនៃកិច្ចព្រមព្រៀងខាងលើអោយមានប្រសិទ្ធិភាពខ្ពស់ ។

សូមលោកប្រធានក្រុមហ៊ុនទាំងពីរទទួលនូវការរាប់អានដ៏ជ្រាលជ្រៅពីខ្ញុំ។

ស៊ុយ សែម

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
Nº [illegible]

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ [illegible] ឆ្នាំ ២០១១

# អាជ្ញាប័ណ្ណស្វែងរុករក (រ៉ែបុកស៊ីត)

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០១/០៩ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០១ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ ។
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។
- បានឃើញកិច្ចព្រមព្រៀងស្តីពីការសិក្សាស្រាវជ្រាវរ៉ែបុកស៊ីតនៅតំបន់ភ្នំទូគួរ ស្រុកអូររាំង និងស្រុក-សែនមនោរម្យ ខេត្តមណ្ឌលគិរី រវាងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងក្រុមហ៊ុន CAMBODIA INTERNATIONAL INVESTMENT DEVELOPMENT GROUP Co., Ltd. ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១០ ។
- បានឃើញអាជ្ញាប័ណ្ណស្វែងរុករកលេខ ៤៩១ ឧរថ.ធរ.អប ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១០ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។
- បានឃើញស្នើសុំចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១១ របស់ក្រុមហ៊ុន CAMBODIA INTERNATIONAL INVESTMENT DEVELOPMENT GROUP Co., Ltd ។
- បានឃើញសេចក្តីកែតម្រូវលេខ ០០១ នៃកិច្ចព្រមព្រៀងស្តីពីការសិក្សាស្រាវជ្រាវរ៉ែបុកស៊ីតនៅតំបន់ភ្នំទូគួរ ស្រុកអូររាំង និងស្រុកសែនមនោរម្យ ខេត្តមណ្ឌលគិរី ចុះថ្ងៃទី [illegible] ។

៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥) ២៣ ២១១ ១៤១ ទូរសារ: (៨៥៥) ២៣ ៤២៨ ២៦៣
45 Preah Norodom Boulivard, Khan Daun Penh, Phone: (855) 23 211 141 Fax: (855) 23 428 263

# សំរេច

<u>ប្រការ១:</u> អនុញ្ញាតអោយក្រុមហ៊ុន C.I.I.D.G ERDOS HONGJUN ALUMINUM INDUSTRY Co., Ltd មានអាសយដ្ឋាននៅផ្ទះលេខ ២៧ ផ្លូវលេខ ៣០៧ សង្កាត់បឹងកក់ ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ធ្វើការសិក្សាស្រាវជ្រាវរ៉ែបុកស៊ីតនៅតំបន់ភ្នំទូគូរ ស្រុកអូររាំង និងស្រុកសែនមនោរម្យ ខេត្តមណ្ឌលគីរី លើផ្ទៃដីទំហំ <u>៣៦០</u> ( បីរយហុកសិប ) គីឡូម៉ែត្រក្រឡា ដែលមាន កូអ័រដោណេដូចតទៅ :

| ចំណុច | អាប់ស៊ីស | អ័រដោណេ | ចំណុច | អាប់ស៊ីស | អ័រដោណេ |
|---|---|---|---|---|---|
| A 01 | $7\ 34^{000}$ | $13\ 64^{300}$ | A 18 | $7\ 61^{350}$ | $13\ 77^{850}$ |
| A 02 | $7\ 35^{950}$ | $13\ 64^{300}$ | A 19 | $7\ 61^{350}$ | $13\ 75^{550}$ |
| A 03 | $7\ 35^{950}$ | $13\ 66^{700}$ | A 20 | $7\ 60^{750}$ | $13\ 75^{550}$ |
| A 04 | $7\ 37^{600}$ | $13\ 66^{700}$ | A 21 | $7\ 60^{750}$ | $13\ 73^{500}$ |
| A 05 | $7\ 37^{600}$ | $13\ 76^{000}$ | A 22 | $7\ 60^{350}$ | $13\ 73^{500}$ |
| A 06 | $7\ 38^{900}$ | $13\ 76^{000}$ | A 23 | $7\ 60^{350}$ | $13\ 70^{750}$ |
| A 07 | $7\ 38^{900}$ | $13\ 77^{000}$ | A 24 | $7\ 58^{000}$ | $13\ 70^{750}$ |
| A 08 | $7\ 40^{500}$ | $13\ 77^{000}$ | A 25 | $7\ 58^{000}$ | $13\ 65^{650}$ |
| A 09 | $7\ 40^{500}$ | $13\ 76^{000}$ | A 26 | $7\ 56^{000}$ | $13\ 65^{650}$ |
| A 10 | $7\ 42^{000}$ | $13\ 76^{000}$ | A 27 | $7\ 56^{000}$ | $13\ 64^{350}$ |
| A 11 | $7\ 42^{000}$ | $13\ 75^{600}$ | A 28 | $7\ 45^{000}$ | $13\ 64^{350}$ |
| A 12 | $7\ 45^{550}$ | $13\ 75^{600}$ | A 29 | $7\ 45^{000}$ | $13\ 61^{500}$ |
| A 13 | $7\ 45^{550}$ | $13\ 81^{500}$ | A 30 | $7\ 43^{500}$ | $13\ 61^{500}$ |
| A 14 | $7\ 50^{000}$ | $13\ 81^{500}$ | A 31 | $7\ 43^{500}$ | $13\ 60^{550}$ |
| A 15 | $7\ 50^{000}$ | $13\ 80^{000}$ | A 32 | $7\ 35^{500}$ | $13\ 60^{550}$ |
| A 16 | $7\ 60^{700}$ | $13\ 80^{000}$ | A 33 | $7\ 35^{500}$ | $13\ 61^{500}$ |
| A 17 | $7\ 60^{700}$ | $13\ 77^{850}$ | A 34 | $7\ 34^{000}$ | $13\ 61^{500}$ |

<u>ប្រការ២:</u> ក្រុមហ៊ុន C.I.I.D.G ERDOS HONGJUN ALUMINUM INDUSTRY Co., Ltd ត្រូវដំណើរការសិក្សាស្រាវជ្រាវរ៉ែបុកស៊ីតលើផ្ទៃដីដែលបានកំណត់ខាងលើ ដោយអនុវត្តទៅតាមផែនការឆ្នាំ និងកម្មវិធីការងាររបស់ខ្លួនដោយធានាអនុវត្តតាមបទដ្ឋានបច្ចេកទេសក្នុងការសិក្សាស្រាវជ្រាវរុករករ៉ែបុកស៊ីត ។

<u>ប្រការ៣:</u> អាជ្ញាប័ណ្ណនេះមានសុពលភាពរហូតដល់ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១២ ។ មុនផុតកំណត់៩០ថ្ងៃ ក្រុមហ៊ុនត្រូវដាក់ពាក្យសុំអនុញ្ញាតធ្វើការសិក្សាស្រាវជ្រាវរ៉ែបន្តជាថ្មី ៕

**ប្រការ៤:** ក្នុងករណីប្រព្រឹត្តល្មើសលើល័ក្ខខ័ណ្ឌនៃកិច្ចព្រមព្រៀងចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១០ អាជ្ញាប័ណ្ណនេះនឹងត្រូវដកហូត ឬត្រូវពិន័យទៅតាមច្បាប់ស្ដីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ ។

**ប្រការ៥:** អគ្គនាយកនៃអគ្គនាយកដ្ឋានធនធានរ៉ែ អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធាននាយកដ្ឋានគណនេយ្យ-ហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានរដ្ឋបាល ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ខេត្តមណ្ឌលគិរី និងក្រុមហ៊ុន C.I.I.D.G ERDOS HONGJUN ALUMINUM INDUSTRY Co., Ltd ត្រូវទទួលអនុវត្តអាជ្ញាប័ណ្ណនេះតាមភារៈកិច្ចរៀងៗខ្លួន។

**ប្រការ៦:** អាជ្ញាប័ណ្ណនេះមានអនុភាពគតិយុត្តិចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ស៊ុយ សែម

**ចំលងជូន**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងបរិស្ថាន
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- សាលាខេត្តមណ្ឌលគិរី
- សាលាស្រុកអូររាំង
- សាលាស្រុកសែនមនោរម្យ
- ដូចប្រការ៥ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ